**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ការប្តូរឈ្មោះ សាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង ទៅជាសាកលវិទ្យាល័យ ធី ធី យូ អ៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខខណ្ឌវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការទទួលស្គាល់ការប្រែក្លាយវិទ្យាស្ថានបច្ចេកវិទ្យានិងគ្រប់គ្រង ទៅជាសាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់ការប្តូរឈ្មោះសាកលវិទ្យាល័យបច្ចេកវិទ្យា និងគ្រប់គ្រង ទៅជា **សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី** "Bright and Brilliant University of Elite" or "University of BBU-e" សរសេរកាត់ជាភាសាខ្មែរ "ស.ប.ប.អ." និងសរសេរកាត់ជាភាសាអង់គ្លេស "B.B.U-e"។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអាគារលេខ ៥៥ ផ្លូវលេខ ១៨០ សង្កាត់ បឹងរាំង ខណ្ឌ ដូនពេញ រាជធានី ភ្នំពេញ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ២ :** សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី មានភារកិច្ច :

-បណ្តុះបណ្តាលអ្នកជំនាញឯកទេសឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់សាកលវិទ្យាល័យ
-បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន និងសាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
-រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា
-សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងជាភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់
-រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀនប្រលងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព
-ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ តាមឯកទេសរបស់សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
-កសាងផែនការអភិវឌ្ឍន៍ សម្រាប់សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
-គ្រប់គ្រងនិស្សិត បុគ្គលិក សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
-ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានាក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ។

**មាត្រា ៣ :** សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សា ត្រូវបានរៀបចំឱ្យមានមហាវិទ្យាល័យប្រាំ :

១-មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
២-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
៣-មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
៤-មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
៥-មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ

ទៅអនាគត សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី អាចប្តូរឈ្មោះ ប្តូរទីតាំង ពង្រីកទីតាំង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេស ឬបើកមហាវិទ្យាល័យសាខា ឯកទេស ឬប្រភេទអប់រំដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤ : សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍សាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៥ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៦ : សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការប្រតិបត្តិមួយរូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៧ : សាកលវិទ្យាធិការប្រតិបត្តិនៃសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ច ដល់អង្គភាពនានាក្រោមឱវាទ
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់ របស់សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី និងគោរពតាមវិធានការណ៍ ស្តីពីការគ្រប់គ្រងបុគ្គលិក
- កំណត់បទបញ្ជាផ្ទៃក្នុងនៃសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

មាត្រា ៨ : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះផ្តល់ឱ្យដោយសាកលវិទ្យាល័យ ប៊ី ប៊ី យូ អ៊ី ហើយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បំពេញ និងអនុវត្តបាន តាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការ ប៊ី ប៊ី យូ អ៊ី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១០*
- *ឯកសារ-កាលប្បវត្តិ* ✓